ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦១៤ ...សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## នីតិវិធីនិងបែបបទសម្រាប់ការស្នើសុំនាំចេញផលិតផលរ៉ែ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Doun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៩៨៨ អនក្រ.បក. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក. ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១** .-

ការស្នើសុំនាំចេញផលិតផលរ៉ែត្រូវអនុវត្តតាមនីតិវិធីនិងបែបបទស្របតាមការកំណត់ក្នុងប្រកាសនេះ។

**ប្រការ២** .-

ផលិតផលរ៉ែដែលអាចស្នើសុំធ្វើការនាំចេញមានដូចខាងក្រោម៖

ក- ផលិតផលរ៉ែដែលបានមកពីរ៉ែឧស្សាហកម្ម រ៉ែលោហៈ និងរ៉ែអលោហៈ។

ខ- ផលិតផលរ៉ែសំណង់ ថ្មក្រានីត ថ្មអារ ឬថ្មប្លុកផ្សេងៗ។

**ប្រការ៣** .-

ដើម្បីអាចនាំចេញផលិតផលរ៉ែបាន អ្នកនាំចេញផលិតផលរ៉ែត្រូវមានឯកសារដូចខាងក្រោម៖

- គោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញ ផ្តល់ដោយក្រសួងរ៉ែនិងថាមពលសម្រាប់ផែនការនាំចេញក្នុងរយៈពេលកំណត់មួយមិនលើសពី១ឆ្នាំ
- វិញ្ញាបនបត្របញ្ជាក់ការនាំចេញសម្រាប់ការនាំចេញជាក់ស្តែងក្នុងមួយលើកៗ ផ្តល់ដោយក្រសួងរ៉ែនិងថាមពល
- វិក្កយបត្របណ្តោះអាសន្ន (Pro-Format Invoice) ឬវិក្កយបត្រពាណិជ្ជកម្ម (Commercial Invoice)
- លិខិតផ្ទុកទំនិញដែលមានការបញ្ជាក់ត្រឹមត្រូវ
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណពន្ធប៉ាតង់ (ឆ្នាំចរន្ត)

- លិខិតបញ្ជាក់ការបំពេញកាតព្វកិច្ចសារពើពន្ធដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ៤.-**

អ្នកនាំចេញផលិតផលរ៉ែដែលមានបំណងនាំចេញផលិតផលរ៉ែ ត្រូវដាក់ពាក្យស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញ ជូនមកក្រសួងរ៉ែនិងថាមពល។

ពាក្យស្នើសុំខាងលើត្រូវមានភ្ជាប់មកជាមួយនូវព័ត៌មាន និងឯកសារ ដូចមានតម្រូវក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៥.-**

ចំពោះសំណើសុំនាំចេញផលិតផលរ៉ែដែលបានមកពីរ៉ែឧស្សាហកម្ម រ៉ែលោហៈ និងរ៉ែអលោហៈ ក្រសួងរ៉ែនិងថាមពលត្រូវធ្វើការវិភាគទៅលើកត្តាសេដ្ឋកិច្ច បរិស្ថាន និងសង្គមហើយធ្វើការសម្រេច៖

- បដិសេធសំណើសុំនាំចេញ ក្នុងករណីដែលសំណើនោះផ្តល់ផលអវិជ្ជមានដល់សេដ្ឋកិច្ច បរិស្ថាន និងសង្គម ឬ
- លើកសំណើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាលតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីក្រសួងផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតនាំចេញផលិតផលរ៉ែ ក្នុងករណីដែលសំណើនោះផ្តល់ផលវិជ្ជមានដល់សេដ្ឋកិច្ច បរិស្ថាន និងសង្គម។

**ប្រការ៦.-**

ចំពោះសំណើសុំនាំចេញផលិតផលរ៉ែសំណង់ ថ្មក្រានីត ថ្មអារ ឬថ្មប្លុកផ្សេងៗ ក្រសួងរ៉ែនិងថាមពលត្រូវធ្វើការវាយតម្លៃយថាប្រភេទ ប៉ាន់ស្មានអំពីសក្តានុពលសេដ្ឋកិច្ចរ៉ែ លក្ខខណ្ឌពាណិជ្ជកម្ម និងបរិមាណកូតាសមស្របសម្រាប់ការនាំចេញ ដើម្បីពិនិត្យនិងសម្រេច ក្នុងការបដិសេធឬផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញ។

**ប្រការ៧.-**

មុនពេលនាំចេញផលិតផលរ៉ែមួយលើកៗ អ្នកនាំចេញផលិតផលរ៉ែត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញពីក្រសួងរ៉ែនិងថាមពល។ ពាក្យស្នើសុំត្រូវមានព័ត៌មាននិងឯកសារភ្ជាប់ដូចមានតម្រូវក្នុងឧបសម្ព័ន្ធទី២ និងទី៣ នៃប្រកាសនេះ។

ក្រសួងរ៉ែនិងថាមពលត្រូវធ្វើការឆ្លើយតបយ៉ាងយូរ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ៨ ..**

អ្នកនាំចេញផលិតផលរ៉ែត្រូវជូនដំណឹងអំពីពេលវេលានៃការផ្ទុកផលិតផលរ៉ែ មកក្រសួងរ៉ែនិងថាមពលក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ)ថ្ងៃ មុនពេលធ្វើការផ្ទុកផលិតផលរ៉ែទៅក្នុងកុងតេនើ ឬមធ្យោបាយដឹកជញ្ជូនផ្សេងទៀតសម្រាប់គោលបំណងនាំចេញ។ ក្រសួងរ៉ែនិងថាមពលត្រូវចាត់មន្ត្រីសមត្ថកិច្ចចុះត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លើយថាប្រភេទផលិតផលរ៉ែ បរិមាណ និងលិខិតស្នាមផ្សេងៗមុននឹងធ្វើការនាំចេញ។ មន្ត្រីសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលត្រូវធ្វើកំណត់ហេតុស្តីពីការត្រួតពិនិត្យការផ្ទុកផលិតផលរ៉ែរួមជាមួយអ្នកនាំចេញផលិតផលរ៉ែ ឬតំណាងអ្នកនាំចេញផលិតផលរ៉ែដែលមានការប្រគល់សិទ្ធិត្រឹមត្រូវពីអ្នកនាំចេញផលិតផលរ៉ែ។

ក្នុងករណីមានការត្រួតពិនិត្យពីមន្ត្រីសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ហើយបានរកឃើញថា យថាប្រភេទផលិតផលរ៉ែ ឬបរិមាណមានការខុសគ្នានឹងវិញ្ញាបនបត្របញ្ជាក់ការនាំចេញរបស់ក្រសួងរ៉ែនិងថាមពល ឬលិខិតស្នាមផ្សេងៗមិនគ្រប់គ្រាន់ឬខុសនឹងការស្នើសុំ មន្ត្រីសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលមានសិទ្ធិ៖

- ស្នើសុំកិច្ចសហការជាមួយមន្ត្រីមានសមត្ថកិច្ចដទៃទៀត បញ្ឈប់ការនាំចេញនេះជាបណ្តោះអាសន្ន និង
- ស្នើសុំគោលការណ៍សម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ដើម្បីផ្អាកការចេញវិញ្ញាបនបត្របញ្ជាក់ការនាំចេញជាបណ្តោះអាសន្ន។

**ប្រការ៩ ..**

បន្ទាប់ពីបានធ្វើការនាំចេញផលិតផលរ៉ែក្នុងមួយជើងៗរួច អ្នកនាំចេញផលិតផលរ៉ែត្រូវធ្វើរបាយការណ៍ជូនមកក្រសួងរ៉ែនិងថាមពលអំពីការនាំចេញផលិតផលរ៉ែនោះ ដោយភ្ជាប់មកជាមួយនូវឯកសារប្រតិវេទន៍នាំចេញបញ្ចប់បែបបទដោយសមត្ថកិច្ចគយ ក្នុងការនាំចេញ យ៉ាងយូរ១០(ដប់)ថ្ងៃក្រោយពីការនាំចេញរួច។

ចំពោះការខកខានមិនបានធ្វើរបាយការណ៍ជូនមកក្រសួងក្រោយពីបានធ្វើការនាំចេញរួច នឹងអាចជាមូលហេតុដែលក្រសួងរ៉ែនិងថាមពល មិនចេញនូវវិញ្ញាបនបត្របញ្ជាក់ការនាំចេញជូនជាបន្តទៀតបាន វហូតទាល់តែអ្នកនាំចេញផលិតផលរ៉ែបានបំពេញនូវកាតព្វកិច្ចខាងលើនេះរួច។

**ប្រការ១០ ..**

រៀងរាល់ការនាំចេញមួយជើងៗ អ្នកនាំចេញត្រូវស្នើសុំលិខិតអនុញ្ញាតនាំចេញពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ មន្ត្រីសមត្ថកិច្ចនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាតាមច្រកនាំចេញដែលពាក់ព័ន្ធ ត្រូវធ្វើសេចក្តីបញ្ជាក់អំពីការកាត់ស្តុកផលិតផលរ៉ែដែលត្រូវបានអនុញ្ញាតនាំចេញជាក់ស្តែងតាមច្រករបស់ខ្លួនស្របតាមលិខិតគោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវធ្វើរបាយការណ៍អំពីការកាត់ស្តុកនៃការនាំចេញផលិតផលរ៉ែរៀងរាល់ដំណាច់ត្រីមាសជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចម្លងជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ដើម្បីផ្ទៀងផ្ទាត់លើបរិមាណដែលក្រសួងរ៉ែនិងថាមពលអនុញ្ញាតឱ្យនាំចេញ។

អគ្គនាយកដ្ឋានធនធានរ៉ែត្រូវធ្វើរបាយការណ៍នៃការនាំចេញផលិតផលរ៉ែ រៀងរាល់ដំណាច់ត្រីមាសជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យបច្ចុប្បន្នភាពនៃការនាំចេញផលិតផលរ៉ែ។

**ប្រការ១១ ..**

ក្នុងរយៈពេលយ៉ាងយូរ ០១ (មួយ) ឆ្នាំម្តង ក្រសួងរ៉ែនិងថាមពលត្រូវធ្វើការពិនិត្យវាយតម្លៃផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម ចំពោះយថាប្រភេទផលិតផលរ៉ែដែលបានអនុញ្ញាតឱ្យនាំចេញ។

ក្នុងករណីមានតម្រូវការសេដ្ឋកិច្ចនិងសង្គមចាំបាច់ ឬដើម្បីដោះស្រាយវិបត្តិតម្រូវការវត្ថុធាតុដើមក្នុងស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញសេចក្តីជូនដំណឹងមកក្រសួងរ៉ែនិងថាមពលអំពីយថាប្រភេទផលិតផលរ៉ែជាក់លាក់ដែលមិនត្រូវអនុញ្ញាតឲ្យធ្វើការនាំចេញ ឬធ្វើការកំណត់កូតារួមក្នុងការអនុញ្ញាតឱ្យនាំចេញយថាប្រភេទផលិតផលរ៉ែណាមួយ។

ការសម្រេចក្នុងកថាខ័ណ្ឌទី២ខាងលើត្រូវគិតគូរអំពីផលប៉ះពាល់ចំពោះការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាពាណិជ្ជកម្មក្រោមគោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញដែលមានស្រាប់។

**ប្រការ១២ ..**

គោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញអាចត្រូវបានព្យួរក្នុងរយៈពេល០៣(បី)ខែ ក្នុងករណីដែលរកឃើញថា អ្នកនាំចេញផលិតផលរ៉ែមានចេតនាធ្វើប្រតិវេទន៍បញ្ជាក់ការនាំចេញផលិតផលរ៉ែមិនពិត ក្លែងបន្លំយថាប្រភេទផលិតផលរ៉ែ ឬបរិមាណផលិតផលរ៉ែនាំចេញមានការខុស

គ្មានឹងលិខិតអនុញ្ញាតរបស់ក្រសួងរ៉ែនិងថាមពល ឬនាំចេញដោយគ្មានលិខិតស្នាមដែលតម្រូវពីស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រាន់។

ក្នុងករណីដែលអ្នកនាំចេញផលិតផលរ៉ែប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងចំណុចណាមួយក្នុងកថាខណ្ឌខាងលើ ក្រសួងរ៉ែនិងថាមពលនឹងដកហូតគោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញទាំងអស់របស់អ្នកនាំចេញផលិតផលរ៉ែ និងមិនផ្តល់ការអនុញ្ញាតឱ្យធ្វើការនាំចេញក្នុងរយៈពេលកំណត់មួយ។

ការព្យួរឬដកហូតគោលការណ៍កំណត់កូតាអនុញ្ញាតឲ្យនាំចេញខាងលើនេះ មិនអនុញ្ញាតឱ្យអ្នកនាំចេញផលិតផលរ៉ែរួចផុតពីទោសទណ្ឌផ្សេងៗទៀតដែលកំណត់ក្នុងច្បាប់ ឬបទប្បញ្ញត្តិជាធរមានឡើយ។

**ប្រការ១៣.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំគោលការណ៍កំណត់កូតានាំចេញផលិតផលរ៉ែ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.............................ភេទ.............អាយុ...........ឆ្នាំ សញ្ជាតិ............................
ជាប្រធាន ក្រុមហ៊ុន/សហគ្រាស.................................................................................................
អាសយដ្ឋានក្រុមហ៊ុន/សហគ្រាស៖ ផ្ទះលេខ.............ផ្លូវ...............................ភូមិ..............................
សង្កាត់/ឃុំ.....................................ខណ្ឌ/ស្រុក..............................រាជធានី/ខេត្ត...................................
ទូរស័ព្ទទំនាក់ទំនងលេខ.................................................អ៊ីមែល.......................................................
កាន់អាជ្ញាបណ្ណធនធានរ៉ែលេខ.....................ចុះថ្ងៃទី........ខែ...........ឆ្នាំ...........

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

**កម្មវត្ថុ៖** សំណើសុំគោលការណ៍កំណត់កូតានាំចេញផលិតផលរ៉ែ.......................................។

អត្ថន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាអនុញ្ញាតផ្តល់នូវគោលការណ៍កំណត់កូតានាំចេញផលិតផលរ៉ែ...................................ក្នុងបរិមាណ..........................................សម្រាប់រយៈពេល...................ចាប់ពីថ្ងៃទី...........................សម្រាប់នាំចេញទៅប្រទេស.......................................ដល់ក្រុមហ៊ុន/សហគ្រាសខ្ញុំបាទ-នាងខ្ញុំដោយអនុគ្រោះ។

សូមគោរពភ្ជាប់ជូននូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

១- ផែនការនាំចេញប្រចាំឆ្នាំ ប្រចាំត្រីមាស និងប្រចាំខែនីមួយ
២- កិច្ចសន្យាលក់ ទិញផលិតផលរ៉ែ និង
៣- ការវិភាគលើការចំណាយ-ផលចំណេញ (cost-benefit analysis)

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

........................ថ្ងៃទី.........ខែ............ឆ្នាំ២០.......

ហត្ថលេខានិងត្រា

ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន.........

# ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................ភេទ..............អាយុ...........ឆ្នាំ សញ្ជាតិ..........................
ជាប្រធាន ក្រុមហ៊ុន/សហគ្រាស..........................................................................................
អាសយដ្ឋានក្រុមហ៊ុន/សហគ្រាស៖ ផ្ទះលេខ.............ផ្លូវ..............................ភូមិ..............................
សង្កាត់/ឃុំ..................................ខណ្ឌ/ស្រុក.................................រាជធានី/ខេត្ត.................................
ទូរស័ព្ទទំនាក់ទំនងលេខ.....................................................អ៊ីមែល..................................................
កាន់អាជ្ញាបណ្ណធនធានរ៉ែលេខ..........................................ចុះថ្ងៃទី............ខែ...............ឆ្នាំ......................
គោលការណ៍កំណត់កូតានាំចេញលេខ.......................ចុះថ្ងៃទី........ខែ............ឆ្នាំ...................

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

**កម្មវត្ថុ៖** សំណើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ..........................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាអនុញ្ញាតផ្តល់នូវវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ....................................ក្នុងបរិមាណចំនួន...........................
មានគោលដៅឆ្ពោះទៅកាន់ប្រទេស............................ជល់ខ្ញុំបាទ-នាងខ្ញុំដោយអនុគ្រោះ។

សូមគោរពភ្ជាប់ជូននូវឯកសារប្រតិវេទន៍បញ្ជាក់ការនាំចេញផលិតផលរ៉ែ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

.........................ថ្ងៃទី.........ខែ............ឆ្នាំ............

ហត្ថលេខានិងត្រា

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរ៉ែ និងថាមពល**
**អគ្គនាយកដ្ឋានធនធានរ៉ែ**

# ប្រតិវេទន៍បញ្ជាក់ការនាំចេញផលិតផលរ៉ែ

ប្រកាសអន្តរក្រសួងលេខ.................................

| | | | |
|---|---|---|---|
| 1- ឈ្មោះអ្នកស្នើសុំ : | 2- ភេទ : ប្រុស ☐ ស្រី ☐ | 3- អាយុ : ឆ្នាំ | 4- សញ្ជាតិ : |
| 5- មុខងារជា : | | | |
| 6 -ឈ្មោះអ្នកតំណាង(ប្រសិនបើប្រគល់សិទ្ធិឲ្យអ្នកតំណាង)(*) : | | | |
| 7- ក្រុមហ៊ុន/សហគ្រាស : | 8-កាន់អាជ្ញាបណ្ណលេខ : ចុះថ្ងៃទី ខែ ឆ្នាំ | | |
| 9- គោលការណ៍កំណត់កូតានាំចេញផលិតផលរ៉ែ | លេខ : ចុះថ្ងៃទី ខែ ឆ្នាំ | | |
| | មានសុពលភាពដល់ ថ្ងៃទី ខែ ឆ្នាំ | | |
| 10- ឈ្មោះផលិតផលរ៉ែ : | 11- បរិមាណ : | 12- ប្រភេទ/គុណភាព : | |
| 13- ក្រុមហ៊ុនទទួលទិញ(**) | ឈ្មោះ : | | |
| | អាសយដ្ឋាន : | | |
| 14- ប្រទេសគោលដៅនាំចេញ : | 15- ជើងនាំចេញទី : | | |
| 16- ត្រូវនាំចេញនៅថ្ងៃទី ខែ ឆ្នាំ | 17- ច្រកនាំចេញ : | | |
| 18- ប្រទេសគោលដៅនាំចេញចុងក្រោយ(ប្រសិនបើមាន) : | | | |
| 19- អត្តសញ្ញាណមធ្យោបាយដឹកជញ្ជូន : យន្តហោះ ☐ រថយន្ត ☐ រថភ្លើង ☐ នាវា ☐ ផ្សេងៗ ☐ | | | |
| 20- ព័ត៌មានអំពីចំណុះផ្ទុកទំនិញ :<br>-យន្តហោះ :<br>-រថយន្ត<br>-រថភ្លើង :<br>-នាវា : | 21- ឯកសារភ្ជាប់មាន :<br>១-វិក័យបត្រពាណិជ្ជកម្ម (Cammercial Invoice) ☐<br>២-លិខិតផ្ទុកទំនិញ (Bill of Lading) ☐<br>(បញ្ជាក់ដោយអង្គភាពកាំសាប) | | |

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

ហត្ថលេខានិងត្រាក្រុមហ៊ុន

សំគាល់ :

(*) ត្រូវភ្ជាប់មកជាមួយនូវលិខិតផ្ទេរសិទ្ធិដែលមានបញ្ជាក់ដោយមេធាវីត្រឹមត្រូវ

(**) ក្នុងករណីក្រុមហ៊ុនទទួលទិញខុសពីភាគីក្នុងកិច្ចសន្យាទិញ-លក់ នៅពេលស្នើសុំកូតាត្រូវផ្តល់កិច្ចសន្យាទិញលក់ថ្មីបន្ថែម

| |
|---|
| សម្រាប់មន្ត្រីសមត្ថកិច្ចក្រសួងរ៉ែនិងថាមពល |
| ........................................................................................ |
| ........................................................................................ |